# ខ្មែរ សុវណ្ណភូមិ

**April 25, 2018** ·

ខួប៦ឆ្នាំនៃការសំលាប់លោក ឈុត វុទ្ធី៖ #ឃាតករនៅរស់
និងសប្បាយលើគំនរឈើចាប់របស់គ្រួសារសព និងរាស្រ្តខ្មែរ
...........................
#ចំពោះមរណៈភាពរបស់លោកឈុតវុទ្ធីត្រូវបានគេមើលឃើញថាវាទាក់ទងនឹងមនុស្សមួយចំនួនដែលគេអាចចាត់ទុកថាជាមេឃាតករដូចជា ហ៊ុន ម៉ាណា ខៀវ សស៊ីលៀប និង ហួ ហាប់ ដោយមានការគាំទ្រពី សៅ សុខា ផងដែរ។
មូលហេតុអ្វីបានជាយើងហ៊ានអះអាងថាជននេះជាប់ពាក់ព័ន្ធនឹងការសំលាប់លោក ឈុត វុទ្ធី?
សូមអានអត្ថបទដូចតទៅ៖
#ហេតុការណ៏ឃាតកម្ម៖ លោក ឈុត វុទ្ធី ទទួលមរណភាព ថ្ងៃទី ២៦ មេសា ២០១២ គឺជាអតីតប្រធាន "អង្គការក្រុមការពារធនធានធម្មជាតិ Natural Resource Protection Group" ពេលចុះពិនិត្យការកាប់បំផ្លាញព្រៃឈើ។
ទីតាំងធ្វើឃាត៖ នៅក្រុមហ៊ុន Timber Green
ជាក្រុមហ៊ុនមួយទទួលបានសិទ្ធិប្រមូលអនុផលព្រៃឈើនៅស្ទឹងតាតៃ នៅខេត្តកោះកុង តែតាមពិតក្រុមហ៊ុននេះមិនត្រឹមតែប្រមូលអនុផលព្រៃឈើទេ តែជាក្រុមហ៊ុនកាប់បំផ្លាញព្រៃឈើ និងរកស៊ីជួញដូរវល្លិ៍រមៀតសម្រាប់ផលិតគ្រឿងញៀនថែមទៀត។ ផ្ទុយទៅវិញក្រុមហ៊ុននេះមិនមានការចុះបញ្ជីត្រឹមត្រូវ គ្មានអាស័យដ្ឋានទំនាក់ទំនងពិតប្រាកដឡើយ នេះបើតាមការផ្សាយរបស់កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១១ ខែធ្នូ ២០១១ (http://www.phnompenhpost.com/national/logging-wild-west)។ ក្រុមហ៊ុននេះមានបីភាគីកាន់កាប់ភាគហ៊ុនគឺ៖
១. ហ៊ុន ម៉ាណា និង ខៀវ សស៊ីលៀប មានភាគហ៊ុន ៥៧,៥% ។
២. ហួ ហាប់ កាន់កាប់២៥,៥%។
៣. ភាគីទី៣ កាន់កាប់១៧%។
ទំនាក់ទំនងបុគ្គលក្នុងក្រុមហ៊ុន៖
១. ហ៊ុន ម៉ាណា និង ខៀវ ស ស៊ីលៀប គឺចាត់ទុកគ្នាដូចបងប្អូនបង្កើត ហើយការពិតនាងគ្រាន់តែជាមនុស្សរកស៊ីឈរឈ្មោះឲ្យ ហ៊ុន ម៉ាណា ប៉ុណ្ណោះ។ ហ៊ុន ម៉ាណា ជាអតីត ប្រពន្ធ ម៉ឹង កុម្ភៈ ត្រូវជាកូនប្រសារ ម៉ឹង សំផន និងត្រូវជាបងថ្លៃរបស់ ម៉ឹង ពន្លក។ ម៉ឹង ពន្លក ត្រូវជាប្តីរបស់ ខៀវ សស៊ីលៀប និងជាកូនចៅរបស់ ហ៊ុន ម៉ាណែត។ ម៉ឹង សំផន ជាឪពុកក្មេក ខៀវ សស៊ីលៀប មានឋានៈជាឧត្តមសេនីយ៍ ជារដ្ឋលេខាធិការក្រសួងការពារជាតិ និងជាអ្នកកាន់កាប់ផ្នែកភស្តុភាក្រសួងការពារជាតិ ហើយត្រូវជាអតីតជន្លងរបស់ ហ៊ុន សែន។ ហ៊ុន ម៉ាណា និង ខៀវ សស៊ីលៀប ក្រៅពីរកស៊ីកាប់ឈើជាមួយគ្នា ពួកគេក៏រកស៊ីខាងសំណង់ជាមួយគ្នាដែរ គឺក្រុមហ៊ុន «អូគីដេរ» ដែលសាងសាង់វីឡា និងផ្ទះផ្វែងលក់។ល។
២. ហួ ហាប់៖ រស់នៅអូស្ត្រាលី មានងារជាឧកញ៉ានៅខ្មែរ ជាអនុប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជន ប្រចាំនៅអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ និងជាប្រធានក្រុមការងារតំបន់៣ ប្រចាំក្រុងស៊ីដនី រដ្ឋញូហ្សៅវ៉ែល និងជាមនុស្សជំនិតរបស់ ហ៊ុន ម៉ាណែត។

ដោយសារតែក្រុមហ៊ុន Timer Green នេះជាកម្មសិទ្ធរបស់កូនចៅត្រកូលហ៊ុន
និងមនុស្សក្នុងបក្សស៊ីភីភីបែបនេះ បានជាគ្រប់ពេលដែលលោក ឈុត វុទ្ធី
ចុះទៅពិនិត្យក្រុមហ៊ុននោះ ឬទៅមើលតំបន់ដែលក្រុមហ៊ុននោះកាប់ឈើ
គឺតែងមានកម្លាំងកងទ័ព ពីកងពលលេខ៧០ ដែលគេស្គាល់ថាជាកងអង្គរក្សផ្ទាល់របស់
ហ៊ុន សែន និងកម្លាំងពីកងរាជអាវុធហត្ថ មករារាំងលោក ឈុត វុទ្ធី គ្រប់ពេល
ហើយការស្លាប់របស់លោក ឈុត វុទ្ធី គឺមានវត្តមាន សន្តិសុខក្រុមហ៊ុន Timber Green និង
កងរាជអាវុធហត្ថជាអ្នកនៅទីនោះ និងពាក់ព័ន្ធដែរ។ នេះហើយក៏ជាមូលហេតុដែល
ពេលធ្វើឃាតភ្លាមគឺគ្រប់ក្រសួងចេញមុខការពារក្រុមហ៊ុន
និងជួយផ្សាយលាក់បាំងមេខ្លោងឃាតករ ហើយពួក ម៉ឹង ពន្លក
ក៏សកម្មក្នុងការបំភ្លៃព័តមាននៅពេលនោះ។
ក្នុងហេតុផលទាំងនេះ
បងប្អូនជនរួមឈាមខ្មែរគិតទៅថាតើមនុស្សដែលមិនបានផលប្រយោជន៍ពីក្រុមហ៊ុននេះ
សំលាប់លោក ឈុត វុទ្ធីបានប្រយោជន៍ស្អីដល់ពួកគេ?
តើអ្នកណាមានអំណាចមកបញ្ជាកងកម្លាំង PM និងកងទ័ពមករារាំងលោក ឈុត វុទ្ធី
បានភ្លាមៗគ្រប់កន្លែងដូចនេះ? ដូច្នេះ មានតែពួកនេះហើយជាឃាតករនោះ។
ដោយៈ ខ្មែរ សុវណ្ណភូមិ
#ឈុតវុទ្ធី #ហួហាប់ឃាតករ #ហ៊ុនម៉ាណាឃាតករ #chhutvuthy

See Translation




តាមព័ត៌មានដែលទទួលបាននាពេលនេះគឺ ខៀវ សស៊ីលៀប គ្រាន់តែជាអ្នកឈរឈ្មោះឲ្យ ហ៊ុន ម៉ាណាប៉ុណ្ណោះ។ ចំពោះរឿងចាត់ការនានាគឺ ហ៊ុន ម៉ាណា ជាអ្នកបញ្ជា រីឯ ហួរ ហាប់ ជាអ្នកប្រតិបត្តិរកស៊ី និងរៀបចំកម្លាំងកងសន្តិសុខនានារបស់ក្រុមហ៊ុន។ ចំពោះអ្នកសំលាប់គឺ និងស្លាបជាមួយលោក ឈុត វុទ្ធី ឈ្មោះ អ៊ិន រតនា ជាមន្ត្រីកងរាជអាវុធហត្ថ ហើយអ្នកគេចោទថាឃាករបន្ទាប់មកគឺឈ្មោះ រ៉ាន់ បូរ័ត្ន ជាសន្តិសុខក្រុមហ៊ុន Timber Green ផ្ទាល់តែម្តង។ បងប្អូនគិតទៅមើល តើ អ្នកណាមកបញ្ជាកងរាជអាវុធហត្ថបាន ហើយកើតហេតុនៅកន្លែងណា និងសន្តិសុខរបស់អ្នកណាជាអ្នករងការចោទជាឃាតករ? តើពួកគេអាចហ៊ានធ្វើដោយគ្មានបញ្ជាបានទេ?

**បញ្ជាក់បន្ថែម៖** ក្រៅពីមានរបបរកស៊ីកាប់ឈើជាមួយគ្នា ពួកគេកំពុងរកស៊ីជាមួយគ្នាដ៏ធំមួយគឺ ការសាងសង់ Orkidé Villa មានតំលៃរាប់រយលានដុល្លារ។ ចំពោះក្រុមហ៊ុនTimber Greenនេះ បើរកក្នុងGoogle Search បងប្អូនបានលទ្ធផលតែរឿងល្បីខាងកាប់បំផ្លាញឈើតែប៉ុណ្ណោះ ហើយក្រុមហ៊ុននេះរកតែLogoជាអ្វីក៏គ្មានផង។


ខៀវ សស៊ីលៀប
ហូ ហាប់
Timber
Green



អ័រគីដេ ឌី រ៉ូយ៉ាល់ នឹងលេចរូបរាងដ៏ល្អឥតខ្ចោះនៅឆ្នាំ ២០១៧ ខាងមុខនេះ ជាមួយទុនសរុប ៤០០ លានដុល្លារ

(ភ្នំពេញ)៖ ខុនដូ អ័រគីដេ ឌី រ៉ូយ៉ាល់ នឹងលេចរូបរាងដ៏ល្អឥតខ្ចោះ នៅឆ្នាំ២០១៧ខាងមុខនេះ ជាមួយទុនសរុប៤០០លានដុល្លារ ស្ថិតលើទីតាំងល្អតាមបណ្តោយផ្លូវ២០០៤ (ម៉ែងា) ក្បែរសាលាអន្តរជាតិ NORTHBRIDGE មានទាំងផ្នែកផ្ទះអាជីវកម្ម Shop House, ផ្នែកផ្ទះវីឡាគ្រប់ប្រភេទយ៉ាងស្រស់ប្រណិត ជាមួយគុណភាពសំណង់ដ៏រឹងមាំ ល្អប្រណិតគ្មានពីសេសម្រាប់លោកអ្នក។

លោកស្រី ឌៀវ សរស៊ីលៀប នាយកាប្រតិបត្តិទូទៅ នៃក្រុមហ៊ុនអ័រគីដេវីឡា បានថ្លែងក្នុងពិធីបើកសម្ពោធការិយាល័យលក់របស់ខ្លួន នៅថ្ងៃទី០៥តុលានេះថា ជាមួយនឹងការគ្រោងបញ្ចប់ការសាងសង់នៅឆ្នាំក្រោយ អ័រគីដេ ឌី រ៉ូយ៉ាល់ ដែលជាគម្រោងខុនដូប្រណិត លំដាប់ខ្ពស់មួយក្នុងរាជធានីភ្នំពេញ យើងបានបើកសម្ពោធការិយាល័យលក់ហើយ ដើម្បីផ្តល់ព័ត៌មានជូនអតិថិជន កាន់តែលម្អិតបន្ថែមទៀត បន្ទាប់ពីការទទួលគាំទ្រខ្ពស់ ពីសំណាក់អតិថិជនទាំងនៅក្នុងស្រុក និងក្រៅស្រុក។


ហួត ហាប់ផន
ជាប់ពាក់ព័ន្ធ
សំណាប់លោក
ឈុត វុទ្ធី
MECCA

…